**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ២០១៨

*សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*

*សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី!*

*សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាល!*

*ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ!*

*លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងបងប្អូនជនរួមជាតិទាំងអស់ជាទីគោរពស្នេហា !.*

ក្នុងឱកាសដ៏មហោឡារិកនៃ **ទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ២០១៨** នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមចូលរួមប្រកបដោយភាពស្និទ្ធស្នាលជាមួយបងប្អូនជនរួមជាតិ ស្របពេលដែលឆ្នាំ ២០១៨ ជាខួបទី ២០ នៃការបង្រួបបង្រួមជាតិ ការរក្សាបានសន្តិភាពពេញលេញជូនប្រទេសជាតិ និងការអភិវឌ្ឍលើគ្រប់វិស័យ។

ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវសារលិខិតថ្វាយ និងប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់ អំពីបុព្វហេតុដែលកម្ពុជាត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្ស ដោយសាររាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាជំរុញឱ្យមានការអភិវឌ្ឍសង្គមជាតិមួយ ដែលអាចធានាឱ្យមានការលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចំពោះការកសាងសង្គមជាតិមួយ ដែលមានលទ្ធិប្រជាធិបតេយ្យ និងដែលគ្រប់គ្រងដោយច្បាប់ រួមជាមួយនឹងការធានាឱ្យមានសមធម៌ក្នុងការទទួលបាននូវសិទ្ធិ និងកាលានុវត្តភាពទាំងឡាយ សម្រាប់ប្រជាជនទូទាំងប្រទេសក្នុងគ្រប់ទិដ្ឋភាព។ រាជរដ្ឋាភិបាលនឹងបន្តទ្រទ្រង់ដល់ដំណើររីកលូតលាស់នៃសេដ្ឋកិច្ចទីផ្សារ ដែលមានលក្ខណៈបើកចំហលំហូរនៃកម្លាំងពលកម្ម ដែលបង្កឱ្យមានបរិយាកាសអំណោយផលសម្រាប់នាំកម្ពុជា ឱ្យសម្រេចចក្ខុវិស័យរបស់ខ្លួននៅឆ្នាំ ២០៣០ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និង ២០៥០ ជាប្រទេសអភិវឌ្ឍន៍។ ក្នុងន័យនេះការពង្រឹងមូលដ្ឋានធនធានមនុស្ស និងការបង្កើនសមត្ថភាពជំនាញជាកត្តាអាទិភាព។

ក្នុងអាណត្តិទី ៥ នៃរាជរដ្ឋាភិបាល ការងារអក្ខរកម្មបានពង្រីកវិសាលភាពរបស់ខ្លួនកាន់តែទូលំទូលាយ ដោយមានការចូលរួមកាន់តែច្រើនពីអ្នកពាក់ព័ន្ធ ជាអាទិ៍ ក្នុងឆ្នាំ ២០១៥ ក្រសួងអប់រំ យុវជន និងកីឡាបាន សហការជាមួយអង្គការយូណេស្កូ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ បើកយុទ្ធនាការអក្ខរកម្មជាតិដើម្បី បង្កើនអត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ ឆ្នាំឡើង ឱ្យបានដល់ ៨៤,៤ ភាគរយ សំដៅសម្រេចគោលដៅទី ៤ នៃការអប់រំសម្រាប់ទាំងអស់គ្នា។ យុទ្ធនាការនេះបានរំដោះអនក្ខរជនចំនួន ៩២ ១២៥ នាក់ ឱ្យឆ្លងផុតពីគ្រោះ មិនចេះអក្សរ។ ជាបន្តបន្ទាប់ ក្រសួងអប់រំ យុវជន និងកីឡាខិតខំលើកយកប្រធានបទកាន់តែទាក់ទាញ និង មានអត្ថន័យ ដូចជា «**អក្ខរកម្មរួមចំណែកកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន**» ។

ជាមួយគ្នានេះ ក្រសួងមហាផ្ទៃក៏បានចូលរួមសហការយ៉ាងល្អប្រសើរផងដែរ ជាក់ស្តែង មន្ត្រីពន្ធនាគារ ៣៣ នាក់ ស្រី ០២ នាក់ ត្រូវបានបណ្តុះបណ្តាលឱ្យក្លាយជាគ្រូអក្ខរកម្ម ដើម្បីបង្រៀនអ្នកជាប់ឃុំឃាំងមួយចំនួន ដែលជាអនក្ខរជននៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ រាជធានី ខេត្ត ដើម្បីឱ្យពួកគាត់ទទួលបាននូវការរៀនសូត្រ មានចំណេះដឹង ជំនាញមុខរបរ ចេះអាន ចេះសរសេរ ចេះគិតលេខ និងចេះដោះស្រាយបញ្ហាដែលពាក់ព័ន្ធទៅនឹង ជីវភាពរស់នៅផ្ទាល់របស់ពួកគាត់ និងមានឱកាសសិក្សាបន្តលើមុខជំនាញវិជ្ជាជីវៈ ដើម្បីរកប្រាក់ចំណូល ក្រោយពី ទទួលបានសិទ្ធិសេរីភាព និងធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ។

បន្ថែមពីលើនេះ នៅតាមរោងចក្រចំនួន ១៧ កម្មករ កម្មការិនីរបស់យើង មានលទ្ធភាពចូលរួមក្នុងកម្មវិធី អក្ខរកម្ម ដែលបង្កឱកាសធ្វើឱ្យការងាររបស់ពួកគេកាន់តែប្រសើរឡើង តាមរយៈការចេះគណនាលេខ ការស្គាល់លេខ គណនី ការវាស់ផលធៀបនិងបរិមាណ ដែលជាមូលដ្ឋានគ្រឹះសម្រាប់អាជីពការងារប្រចាំថ្ងៃមានប្រាក់ចំណូលខ្ពស់ ហើយក៏ជាប្រយោជន៍ដល់ម្ចាស់រោងចក្រផងដែរ។

សមិទ្ធផលនៃការអនុវត្តកម្មវិធីអក្ខរកម្មដែលសម្រេចបាននេះ បង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់របស់ រាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមរបស់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ជាពិសេសកិច្ចខិតខំប្រឹងប្រែងអស់ពី កម្លាំងកាយចិត្តរបស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ព្រះសង្ឃ បញ្ញវន្ត ម្ចាស់រោងចក្រសហគ្រាស សិស្ស និងនិស្សិតទូទាំងប្រទេស។

នៅឆ្នាំ ២០១៨ នេះ ទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ «**អក្ខរកម្មឆ្ពោះទៅ ការសិក្សាពេញមួយជីវិត**» ជាមួយនឹងចក្ខុវិស័យ អភិវឌ្ឍប្រជាជនកម្ពុជាគ្រប់រូបឱ្យទទួលបានឱកាសសិក្សា ពេញមួយជីវិត ក្នុងគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បទា ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម។ ទស្សនាទាន នៃប្រធានបទនេះ មិនសំដៅត្រឹមតែការរៀនអក្ខរកម្ម ចេះអក្សរ ចេះលេខនព្វន្តប៉ុណ្ណោះទេ គឺបានគិតគូរដល់ឱកាស ក្នុងការទទួលបានចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញវិជ្ជាជីវៈ និងនវានុវត្តគ្រប់ផ្នែក គ្រប់វិស័យ ជាពិសេស អក្ខរកម្មបច្ចេកវិទ្យា ដែលសព្វថ្ងៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។

***ជនរួមជាតិជាទីស្នេហា!***

ក្នុងបរិការណ៍នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ និងដើម្បីផ្សារភ្ជាប់ការងារអក្ខរកម្ម ទៅនឹងការសិក្សាពេញមួយជីវិត ជាពិសេសការឈានទៅសម្រេចបាននូវគោលដៅ ប្រែក្លាយពលករដែលប្រើ

កម្លាំងសុទ្ធទៅជាការប្រើប្រាស់ជំនាញ ស្របតាម «*យុទ្ធសាស្ត្រកំណើនថ្មី*» របស់កម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ស្ថាប័នជាតិ អន្តរជាតិ សហគមន៍ និងប្រជាជនគ្រប់រូប សូមយកចិត្តទុកដាក់ខ្ពស់ ជាបន្តទៀត ដល់ការងារអក្ខរកម្ម ក៏ដូចជាការងារអប់រំទាំងនៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

ក្នុងស្មារតីនេះ ដើម្បីបន្តចូលរួមលើកកម្ពស់ការងារអក្ខរកម្មនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដូចតទៅ៖

**ទី១-** ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំគោលនយោបាយ ក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការចាំបាច់ ដើម្បីដឹកនាំ គ្រប់គ្រង និងអនុវត្តឱ្យមានប្រសិទ្ធភាព និងគុណភាព ធានាបាននូវលទ្ធភាពទទួលបាន ការសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប និងស្របទៅនឹងបរិការណ៍ថ្មីនៃគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព។

**ទី ២-** ក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា មណ្ឌលសិក្សា ទីវត្តអារាមទាំងអស់ត្រូវបង្កើតកម្មវិធីអប់រំ កម្មវិធី សិក្សាពេញមួយជីវិត ទាំងខាងផ្នែកអក្ខរកម្ម និងវិជ្ជាជីវៈ ឱ្យកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបនឹងតម្រូវការអ្នកសិក្សា ដើម្បីផ្តល់សេវាអប់រំមួយជីវិត ទាំងសេវាអប់រំក្នុងប្រព័ន្ធ អប់រំក្រៅប្រព័ន្ធ និងអប់រំមិនផ្លូវការ ដល់ប្រជាជនគ្រប់រូប។

**ទី៣-** អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រឱ្យបានខ្លាំងក្លាបន្ថែមទៀត ក្នុងការ អភិវឌ្ឍមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសិក្សា ព្រមទាំងជំរុញប្រជាជន ដែលមិនបាន រៀនសូត្រ ឬបោះបង់ការសិក្សា ឱ្យមានឱកាសទទួលបានការរៀនសូត្រជាថ្មី នៅតាមកម្មវិធីអប់រំក្រៅ ប្រព័ន្ធគ្រប់រូបភាព ជាពិសេសត្រូវខិតខំបង្កលក្ខណៈងាយស្រួល ដល់ប្រជាជនដែលមានពិការភាពឱ្យ ទទួលបានលទ្ធភាពក្នុងការសិក្សារៀនសូត្រ។

**ទី៤-** ប្រព័ន្ធផ្សព្វផ្សាយទាំងអស់រួមមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋ និងឯកជន សូមជួយផ្សព្វផ្សាយ និងបញ្ជ្រាបឱ្យបានកាន់តែទូលំទូលាយ អំពីសារៈសំខាន់នៃការងារអក្ខរកម្ម ដើម្បីឱ្យប្រជាជនយើងកាន់តែមានការយល់ដឹងកាន់តែច្រើនអំពី **«អក្ខរកម្មឆ្ពោះទៅការសិក្សាពេញមួយជីវិត»**។

**ទី៥-** ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្រុមយុវជននៃសហភាព សហព័ន្ធយុវជនកម្ពុជា យុវជនកាយរឹទ្ធិ និងយុវជនកាកបាទក្រហមកម្ពុជា ត្រូវចូលរួមឱ្យកាន់តែសកម្ម ក្នុងការចុះជួយបង្រៀនដោយស្ម័គ្រចិត្ត នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលស្ថិតក្នុងមូលដ្ឋាន របស់ក្មួយៗរស់នៅ។ ចំណែក បងប្អូនជនរួមជាតិដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល ក៏សូមជួយ ជំរុញបងប្អូនកូនចៅឱ្យបានចូលរៀនតាមសាលារៀនចំណេះទូទៅគ្រប់ៗគ្នា។ ដោយឡែកក្មួយៗ និង បងប្អូនដែលពុំទាន់ចេះអក្សរ ឬបោះបង់ការសិក្សា ចូរខិតខំប្រឹងប្រែងរៀនសូត្រ នៅតាមថ្នាក់អក្ខរកម្ម ថ្នាក់ សមមូល និងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលនៅជិតភូមិឋានរបស់ខ្លួន។

**ទី៦-** វត្តអារាម និងវិហារសាសនា នានា ត្រូវចលនាព្រះសង្ឃ បព្វជិតសាសនា តាជី ដូនជី ចូលរួមជំរុញ កម្មវិធីអក្ខរកម្មវិជ្ជាជីវៈឱ្យកាន់តែខ្លាំងក្លាថែមទៀត តាមរយៈការទេសនាអប់រំ អំពីសារៈប្រយោជន៍នៃការ រៀនសូត្រ អំពីសីលធម៌ និងលើកកម្ពស់វប្បធម៌រស់នៅជាពលរដ្ឋសកល។

**ទី៧-** ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបង្កើនកិច្ចសហការ និងពង្រឹងភាពជាដៃគូកាន់តែខ្លាំងថែមទៀត ក្នុងការជួយឧបត្ថម្ភ គាំទ្រដល់កម្មវិធីនានា ជាពិសេសកម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងការអប់រំវិជ្ជាជីវៈឱ្យមានដំណើរការល្អជាប់ជាប្រចាំ។

**ទី៨-** ប្រធានរោងចក្រ សហគ្រាស និងក្រុមហ៊ុនឯកជន សូមជួយសហការ និងបង្កលក្ខណៈក្នុងការបើកថ្នាក់អក្ខរកម្ម គួបផ្សំជាមួយថ្នាក់បំប៉នមុខជំនាញវិជ្ជាជីវៈផ្សេងៗដល់បងប្អូនកម្មករ កម្មការិនី ដើម្បីជាប្រយោជន៍របស់ពួកគេផង និងជាប្រយោជន៍ម្ចាស់រោងចក្រ សហគ្រាសផង ដោយយើងទាំងអស់គ្នាត្រូវចងចាំថា «**មានអក្ខរកម្ម មានការគិតគូរនិងការសម្រេចចិត្តបានត្រឹមត្រូវ**» «**មានអក្ខរកម្មនាំឱ្យ សេដ្ឋកិច្ចជាតិកាន់តែរីកចម្រើន**» «**មានអក្ខរកម្ម មានសុខដុមជីវិតបុគ្គល និងសង្គម** »។

ជាថ្មីម្តងទៀត ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សប្បុរសជននានា ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនា និងប្រជាពលរដ្ឋទាំងអស់ ដែលបាននិងកំពុងជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្ម ដល់ការងារអក្ខរកម្មនាពេលកន្លងមក។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សង្ឃឹមថា ការប្រារព្ធ **ទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ២០១៨** នឹងបន្តដាស់ស្មារតីយើងទាំងអស់គ្នាឱ្យចូលរួមក្នុងការងារនេះកាន់តែសកម្មរស់រវើកថែមទៀត។

ជាទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរ និងប្រគេនពរ សម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ២ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៨

ហ៊ុន សែន